# ម៉ូឌុល ១១ : កិច្ចពិភាក្សានិងការសង្ខេប

ឆ្លងតាមការសិក្សារបស់អ្នកនៃម៉ូឌុលផ្សេងៗជាច្រើន អ្នកបានរៀនអំពីប្រភេទផ្សេងគ្នាៗនៃកម្មសិទ្ធិបញ្ញា និងប្រភេទខុសៗនៃកិច្ចការពារ។ ម៉ូឌុលនេះ បានសង្កត់ធ្ងន់ពីអត្ថប្រយោជន៍នៃទម្រង់ជាច្រើន ក្នុងកិច្ចការពារនៅក្នុងលក្ខខណ្ឌនៃអ្នកកាន់កាប់សិទ្ធិ។ ប្រធានបទក្នុងគ្រប់មូលដ្ឋានទាំងអស់នៃការពន្យល់ទាំងនេះគឺថា អ្នកបង្កើតកម្មសិទ្ធិបញ្ញាអាចបង្កើតបានផលតបស្នងជាហិរញ្ញវត្ថុ ដោយការប្រើប្រាស់សិទ្ធិរបស់ពួកគេ។ ជាធម្មតាម្ចាស់កម្មសិទ្ធិបញ្ញាមិនបង្កើតលុយទេ។ ដើម្បីបង្កើតប្រាក់ចំណូល ម្ចាស់សិទ្ធិត្រូវតែទាញយកតាមរយៈប្រភេទផ្សេងនៃកិច្ចព្រមព្រៀងពាណិជ្ជកម្ម រួមទាំងការផ្តល់អាជ្ញាប័ណ្ណ និង ឬផ្ទេរសិទ្ធិ ។ នៅក្នុងន័យនេះ គ្រប់កិច្ចព្រមព្រៀងពាណិជ្ជកម្មទាំងអស់ គឺព្យាយាមបង្វែរកម្មសិទ្ធិបញ្ញា ទៅជា **មូលធនបញ្ញា** ។

សម្លេងមួយចំនួនបន្ទាប់ មានរយៈពេលយូរជាងធម្មតា អ្នកគួរប្រើពួកវាដើម្បីជួយអ្នកនឹកឃើញឡើងវិញពីគោលគំនិត ដែលបានរៀននៅក្នុងម៉ូឌុលមុនៗ ក៏ដូចជាការស្តាប់ដើម្បីជាឧទាហរណ៍នៃការបង្កើតទ្រព្យសម្បត្តិពីកម្មសិទ្ធិបញ្ញា ។

© WIPO/OMPI

**សម្លេងទី ១**: *ឥឡូវនេះ ខ្ញុំបានឮជាច្រើនអំពីកម្មសិទ្ធិបញ្ញា ប៉ុន្តែក៏មានការបញ្ចេញមតិពីមូលធនបញ្ញា ។ តើវាមានភាពខុសគ្នា ដូចម្តេចខ្លះ?*

កម្មសិទ្ធិបញ្ញា ត្រូវបានផ្អែកលើច្បាប់ផ្តល់កិច្ចការពារនៃការបង្កើតណាមួយពីបញ្ញា ដូចជាការបង្កើតថ្មី ខ្សែភាពយន្ត សៀវភៅ តន្ត្រីជាដើម។ មូលធនបញ្ញា រួមបញ្ចូលទាំងកម្មសិទ្ធិបញ្ញា ប៉ុន្តែក៏មានរឿងផ្សេងៗទៀតដែលក្រុមហ៊ុនមួយ អាចប្រើដើម្បីទទួលបានកន្លែងឈរជើងមួយនៅក្នុងទីផ្សារ ជាឧទាហរណ៍ បញ្ជីឈ្មោះអតិថិជន វិធីសាស្រ្តបណ្តុះបណ្តាល វិធីសាស្រ្តត្រួតពិនិត្យគុណភាព ឬ នីតិវិធីធ្វើតេស្តគុណភាព។ ទាំងអស់នេះគឺជាមូលធនបញ្ញា ប៉ុន្តែយើងមិនគួរភ្លេចថាមូលធនបញ្ញាដ៏ធំបំផុតរបស់ក្រុមហ៊ុនគឺជាកម្លាំងពលកម្ម។

កម្មសិទ្ធិបញ្ញា មិនតែងតែជាមូលធនបញ្ញាទេ ក្នុងន័យរូបិយវត្ថុបែបចង្អៀត ដោយសារតែប្រកាសនីយប័ត្រតក្កកម្មមួយ សម្រាប់ការច្នៃប្រឌិតមួយដែលមិនបានដាក់នៅលើទីផ្សារ និង ប្រើដើម្បីបង្កើតប្រាក់ចំណូលសម្រាប់ក្រុមហ៊ុននោះ គឺមិនមែនតម្លៃដែល ក្រដាសត្រូវបានបោះពុម្ពទេ ។ ប្រកាសនីយប័ត្រតក្កកម្មសម្រាប់ការច្នៃប្រឌិតមួយ ដែលត្រូវបានប្រើនៅក្នុងបរិស្ថានពាណិជ្ជកម្ម វានឹងផ្តល់ឲ្យក្រុមហ៊ុននូវគុណសម្បត្តិប្រកួតប្រជែងមួយ ដោយប្រើវា និង ការទប់ស្កាត់អ្នកដទៃពីការដាក់ផលិតផលស្រដៀងគ្នានៅលើទីផ្សារ ក្រុមហ៊ុននេះអាចបង្កើនប្រាក់ចំណេញ ។ ការអនុវត្តដូចគ្នាក្នុងការចុះបញ្ជីពាណិជ្ជសញ្ញា ។ ម៉ាកពាណិជ្ជកម្មដែលមិនស្គាល់ជាសាធារណៈ គឺមិនមានតម្លៃច្រើននោះទេ ប៉ុន្តែម៉ាកដូចជាកូកាកូឡា និយាយថាមានតម្លៃរាប់ពាន់លាន ។ ប៉ុន្តែមនុស្សមួយចំនួននិយាយថា ម៉ាកកូកាកូឡា មិនមានតម្លៃដោយវាមិនដែលត្រូវបានដាក់លក់។ ដូច្នេះ យើងត្រូវធ្វើឲ្យមាន ភាពខុសគ្នារវាង ថ្លៃដើម ថ្លៃលក់ និងតម្លៃរបស់វា។

*តើអ្នកបែងចែកឲ្យខុសគ្នារបៀបណា?*

តម្លៃម៉ាកមួយ ជាការពិតអាស្រ័យលើតម្លៃប៉ុន្មានដែលនរណាម្នាក់ត្រៀមខ្លួនជាស្រេចដើម្បីចំណាយក្នុងការទទួលបានវា។ ឧទាហរណ៍ ប្រសិនបើនរណាម្នាក់ត្រៀមខ្លួនជាស្រេច ក្នុងការបង់ថ្លៃមួយលានដុល្លារសម្រាប់ម៉ាកមួយ ដែលអាចនឹងមានតម្លៃនោះ ប៉ុន្តែវាមិនមែនជាថ្លៃលក់ ដោយសារតែម្ចាស់ប្រហែលជាមិនចង់លក់ ។ ដូច្នេះ មិនមានការកំណត់តម្លៃបានទេ ប្រសិនបើមិនមានប្រតិបត្តិការ តម្លៃនេះនឹងត្រូវបានកំណត់ដោយប្រតិបត្តិការរបស់វា។ ហើយកម្មសិទ្ធិបញ្ញាក្លាយទៅជាតម្លៃដែលគេស្គាល់ ប្រសិនបើវាត្រូវបានផ្តល់ជូននៅលើទីផ្សារ ហើយមាននរណាម្នាក់ត្រៀមខ្លួនជាស្រេចដើម្បីទិញវា។

© WIPO/OMPI

លើកគំរូនៃការច្នៃប្រឌិតមួយ ជាឧទាហរណ៍ វាយនភ័ណ្ឌអាចជាប់ស្អិតគ្នា Velcro ដ៏ល្បីល្បាញ ត្រូវបានបង្កើតដោយអ្នកច្នៃប្រឌិតជនជាតិស្វីស ដែលជាអកុសលមិនបានរកប្រាក់ច្រើនចេញពីការប្រឌិតរបស់គាត់ទេ ដែលនាពេលបច្ចុប្បន្ននេះត្រូវបានគេប្រើនៅគ្រប់ទីកន្លែង ដោយសារតែលោកមិនអាចទទួលបានវានៅលើទីផ្សារពេញមួយជីវិតនៃប្រកាសនីយបត្រតក្កកម្ម Velcro នេះ។ ជាការពិត ប្រាក់ចំណូលតែមួយគត់របស់គាត់គឺមកពីកិច្ចសន្យាជាមួយអង្គការណាសា ដែលបានប្រើផ្នែកមួយនៃការបង្កើតថ្មីរបស់លោកសម្រាប់សំលៀកបំពាក់អវកាសរបស់អវកាសយានិកខ្លួន។ ទោះជាយ៉ាងណា ក្នុងពេលនេះការបង្កើតថ្មីនេះ បានបង្កើតកិច្ចព្រមព្រៀងប្រាក់ចំណូលដ៏អស្ចារ្យ សម្រាប់អ្នកប្រើក្រោយៗដែលបានប្រើវា តាំងពីវាបានក្លាយជាទ្រព្យសម្បត្តិសាធារណៈ ក្រុមហ៊ុនដែលប្រើ Velcro ពេលបច្ចុប្បន្ននេះមិនមានបង់ប្រាក់ថ្លៃសិទ្ធិ ឬថ្លៃអាជ្ញាប័ណ្ណណាមួយទៅឱ្យអ្នកបង្កើតនោះទេ។ នេះ គឺគ្រាន់តែជាឧទាហរណ៍មួយ។ ការបង្កើតថ្មីផ្សេងទៀត បានបង្កើតចំណូលយ៉ាងសន្ធឹកសន្ធាប់ដល់ម្ចាស់ ខ្ញុំក៏អាចផ្តល់ឱ្យអ្នកនូវគំរូនៃប្រព័ន្ធ Dolby នៃការកាត់បន្ថយសម្លេងរំខាន សម្រាប់សម្លេងសុទ្ធកំរិតខ្ពស់របស់ឧបករណ៍បំពងសម្លេងដែលត្រូវបានបង្កើត ហើយបន្ទាប់មកមានប្រសិទ្ធិភាពទីផ្សារ ដោយមធ្យោបាយនៃកិច្ចព្រមព្រៀងអាជ្ញាប័ណ្ណនៅទូទាំងវិស័យឧស្សាហកម្ម និង ការប្រើប្រាស់ផ្សេងៗទៀតដែលបានបង្ហាញ គុណសម្បត្តិនៃប្រពន្ធ័ Dolby សម្រាប់អាជ្ញាប័ណ្ណ នៅពេលដែលបច្ចេកវិទ្យាត្រូវបានផ្តល់ជូនអ្នកប្រើប្រាស់ ពោលគឺអ្នកប្រើប្រាស់ស្វែងរកតន្ត្រីដែលមានគុណភាពល្អគ្មានគូប្រៀប ។

*ដូច្នេះជាសង្ខេប ដូចដែលខ្ញុំដឹងបន្តិចបន្តួចពីប្រព័ន្ធនេះ ការរៀបចំផ្តល់អាជ្ញាប័ណ្ណនេះគឺថាក្រុមហ៊ុនផលិតទាំងអស់ដែលបានបញ្ចូលបច្ចេកវិទ្យានេះត្រូវបង់ថ្លៃអោយ Dolby ?*

វាគឺអញ្ចឹង។ ក្រុមហ៊ុនផលិតទាំងអស់ត្រូវ បង់ថ្លៃក្នុងការប្រើប្រព័ន្ធ Dolby ក្នុងលក្ខខណ្ឌជាក់លាក់ ជាឧទាហរណ៍គាត់មានកាតព្វកិច្ចដើម្បីធ្វើឱ្យវាច្បាស់ដល់អតិថិជនថា ប្រព័ន្ធ Dolby កំពុងត្រូវបានប្រើប្រាស់ ដែលជាការផ្សព្វផ្សាយដោយប្រយោលពីម្នាក់ទៅម្នាក់ ហើយគ្មាននរណាម្នាក់អាចប្រើប្រព័ន្ធ Dolby ដោយគ្មានការចុះកិច្ចព្រមព្រៀងអាជ្ញាប័ណ្ណជាមួយម្ចាស់បានទេ ។

*តើអ្នកមានឧទាហរណ៍មួយទៀតពីរបៀបដែលកម្មសិទ្ធិបញ្ញា អាចធ្វើឲ្យពាណិជ្ជកម្មជោគជ័យដែរឬទេ ?*

© WIPO/OMPI

យើងទាំងអស់គ្នាដឹងពីភាពខ្លាំងរបស់ក្រុមហ៊ុនឱសថ ក្នុងវិស័យកម្មសិទ្ធិបញ្ញាដូចម្ដេចទេ ។ ក្រុមហ៊ុនឱសថទាំងអស់ នៅពេលដែលពួកគេវិនិយោគនៅក្នុងការអភិវឌ្ឍនៃការព្យាបាលថ្មី ថ្នាំពេទ្យនិងថ្នាំ រំពឹងថានឹងជាអ្នកផ្គត់ផ្គង់តែមួយគត់នៅលើទីផ្សារសម្រាប់រយៈពេលមួយ ដូច្នេះពួកគេអាចរកប្រាក់ចំណេញកាន់តែច្រើន ប្រសិនបើមានក្រុមហ៊ុនច្រើនជាងមួយកំពុងផ្ដល់ផលិតផលដូចគ្នា។

អ្នកសម្គាល់ឃើញថា ថ្នាំវេជ្ជសាស្ត្រថ្មីមួយចំនួនបានលេចឡើងនៅលើទីផ្សារក្នុងតម្លៃមួយយ៉ាងខ្ពស់ប្រៀបទៅនឹងការចប់អាយុកិច្ចការពារប្រកាសនីយបត្រតក្កកម្ម ដែលតម្លៃធ្លាក់ទាបសម្រាប់អ្នកប្រើប្រាស់ដូចទម្រង់ទូទៅលេចឡើងនៅលើទីផ្សារ។ ទម្រង់ទូទៅជាការពិតថ្នាំដូចគ្នា និងរូបមន្តដូចគ្នានេះដែរ ប៉ុន្តែប្រកាសនីយបត្រតក្កកម្មរបស់ពួកគេបានផុតកំណត់ និង បច្ចេកវិទ្យាគឺស្ថិតជារបស់សាធារណៈ។ ក្រុមហ៊ុនឱសថព្យាយាមរក្សាអត្ថប្រយោជន៍របស់ពួកគេ ដោយពង្រីកទីផ្សារតាមរយៈពាណិជ្ជសញ្ញាទាក់ទងទៅនឹងថ្នាំជាក់លាក់នេះ។ គ្មាននរណាទេ ប៉ុន្តែក្រុមហ៊ុន Bayer អាចផលិតថ្នាំអាស្ពីរីន Bayer បច្ចុប្បន្ននេះដោយសារតែម៉ាកនេះជាកម្មសិទ្ធិរបស់ក្រុមហ៊ុន។ ទោះជាយ៉ាងណា មានក្រុមហ៊ុនជាច្រើនដែលផលិតថ្នាំវេជ្ជសាស្ត្រ ជាមួយនឹងសមាសធាតុដូចគ្នានឹងថ្នាំអាស្ពីរីន មានប្រសិទ្ធិភាពដូចគ្នានេះដែរ ប៉ុន្តែពួកគេប្រើឈ្មោះផ្សេង។ ដូច្នេះអតិថិជនអាចត្រូវបានដកចេញពីឈ្មោះដើម និង គុណភាពល្បីរបស់ម៉ាក Bayer នោះ ប៉ុន្តែនៅពេលដែលគាត់ត្រូវបានបញ្ចុះបញ្ចូលថា គាត់អាចទិញផលិតផលជំនួសសម្រាប់តម្លៃដូចគ្នា ឬ មានតម្លៃថោកជាង បន្ទាប់មកនោះគឺ ប្រហែលជាអ្វីដែលគាត់នឹងធ្វើ។

*ដូច្នេះ តាមឧទាហរណ៍ អ្នកត្រូវបានបង្ហាញទាក់ទងនឹងទម្រង់ពីរនៃកិច្ចការពារមានប្រកាសនីយបត្រតក្កកម្ម ដែលឥឡូវបានផុតកំណត់ និង ពាណិជ្ជសញ្ញា តើណាមួយចូលមកបន្ត ?*

វាជាការត្រឹមត្រូវ។ ពាណិជ្ជសញ្ញា មិនដូចប្រកាសនីយបត្រតក្កកម្មទេ វាអាចត្រូវបានរក្សាទុកជារៀងរហូតនៅជានិរន្តរ៍។ ហើយវាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ក្រុមហ៊ុនដែលផលិតផលិតផលមូលដ្ឋាន។ ពាណិជ្ជសញ្ញាជាធម្មតាប្រើជាមួយផលិតផលមូលដ្ឋានមានសារៈសំខាន់តិចជាងពេលប្រើជាមួយផលិតផលឯកទេស ។ ផលិតផលឯកទេស ខ្ញុំមានន័យថា ជាឧទាហរណ៍ ឧបករណ៍បង្កើតឡើងមានគោលបំណងច្បាស់ ឬ គ្រឿងម៉ាស៊ីនរុក

© WIPO/OMPI

រកវ៉ែ ឬ គ្រឿងម៉ាស៊ីនខូង។ នៅក្នុងករណីនេះ អ្នកប្រើប្រាស់ឧស្សាហកម្ម មិនបានប្រើប្រាស់ពាណិជ្ជសញ្ញា ដើម្បីនាំឱ្យគេស្គាល់ផលិតផលនោះទេ គាត់នឹងទិញបច្ចេកវិទ្យា ហើយបន្ទាប់មកមានតែសំរាប់ ១០ ឬ ១៥ ឆ្នាំ។ ដូច្នេះ គេសម្លឹងមើលបច្ចេកវិទ្យា ដូចអ្វីដែលគាត់ចង់បានគុណភាព និង ឧបករណ៍ល្អបំផុតសម្រាប់លុយរបស់គាត់ ហើយពាណិជ្ជសញ្ញា បើសិនវាមានប្រភពច្បាស់ទៅប្រភេទផលិតនៃឧបករណ៍គឺបន្ទាប់ នឹងយោងទៅនឹងកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុនផលិត។ នៅក្នុងទីផ្សាររប្រើប្រាស់ដ៏ធំមួយ ពាណិជ្ជសញ្ញាមួយមានឥទ្ធិពលដ៏មានអានុភាព : មនុស្សទិញជាមួយភ្នែក និងដៃរបស់ពួកគេ បន្ទាប់មកទើបគេពិនិត្យមើលអ្វីដែលនៅក្នុងប្រអប់។

© WIPO/OMPI

ដូច្នេះ ជំហានគន្លឹះនៃពាណិជ្ជកម្មតម្រូវឲ្យមានការពិចារណា ប្រសិនបើ អត្ថប្រយោជន៍សេដ្ឋកិច្ច នៃកិច្ចការពារសិទ្ធិកម្មសិទ្ធិបញ្ញាត្រូវទទួលបាន ។

មនុស្សមួយចំនួនគិតថា អត្ថប្រយោជន៍នៃកិច្ចការពារកម្មសិទ្ធិបញ្ញាពាក់ពន្ធ័តែជាមួយប្រទេសឧស្សាហកម្ម ដូច្នេះសូមស្តាប់សម្លេងថតបន្ទាប់នេះ ដែលថ្លែងជាពិសេសពីអត្ថប្រយោជន៍សេដ្ឋកិច្ចដល់ប្រទេសសម្រាប់ការអភិវឌ្ឍ ពីកិច្ចការពារកម្មសិទ្ធិបញ្ញា និងការធ្វើពាណិជ្ជកម្ម មានប្រសិទ្ធិភាព។

**សំលេងទី ២:** *តើអ្នកអាចប្រាប់ពីអត្ថប្រយោជន៍សេដ្ឋកិច្ចនៃកម្មសិទ្ធិបញ្ញា សម្រាប់ប្រទេសកំពុងអភិវឌ្ឍបានឬទេ ?*

ប្រាកដណាស់ ។ ប្រទេសកំពុងអភិវឌ្ឍអាចទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធកម្មសិទ្ធិបញ្ញាដូចគ្នានឹងបណ្តាប្រទេសឧស្សាហកម្ម ។ គុណវិបត្តិ សម្រាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ នាពេលបច្ចុប្បន្ននេះ គឺថាក្រុមហ៊ុនរបស់ពួកគេជាច្រើនមិនបានឲ្យតម្លៃពេញលេញ ពីរបៀបប្រើប្រាស់ប្រព័ន្ធកម្មសិទ្ធិបញ្ញាសម្រាប់អត្ថប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេ។ ប៉ុន្តែដោយមានការយល់ដឹងកើនឡើង ផលិតផលមួយចំនួនចាប់ផ្តើមមាននៅលើទីផ្សារ ខ្ញុំមិនអាចផ្តល់នូវឧទាហរណ៍ដ៏ពិតប្រាកដនោះទេ ប៉ុន្តែការនិយាយជាទូទៅ ក្រុមហ៊ុនចម្រុះជាតិសាសន៍ឥណ្ឌាទិញ និងលក់ផលិតផលមានម៉ាក ដែលមានសេចក្តីយោងសម្រាប់អតិថិជនរបស់ពួកគេ ដូច្នេះ អតិថិជនទៅនិងអាចរកឃើញផលិតផលរបស់ពួកគេកំពុងស្វែងរក ដោយសារពួកគេដឹងពីប្រភពដើមផលិតផល និងប្រើវាជាសូចនាករគុណភាព។

នៅក្នុងបច្ចេកវិទ្យាដូចគ្នា ប្រសិនបើ មជ្ឈមណ្ឌលស្រាវជ្រាវមួយ នៅក្នុងប្រទេសកំពុងអភិវឌ្ឍបង្កើតបច្ចេកវិទ្យាមួយដែលអាចមានប្រយោជន៍ ដល់ប្រទេសមួយទៀត និងមិនមានសុវត្ថិភាពប្រកាសនីយបត្រតក្កកម្មសម្រាប់ការច្នៃប្រឌិត ឬ គំនូរឧស្សាហកម្មរបស់ខ្លួន វានឹងបាត់បង់អត្ថប្រយោជន៍របស់ខ្លួន។ វានឹងបាត់បង់លទ្ធភាពនៃការលក់បច្ចេកវិទ្យា និងប្រាក់ចំណូលបន្ថែម សម្រាប់ផលិតផលពីបញ្ញារបស់ខ្លួន។ ឧទាហរណ៍មួយទៀតក្នុងគំនិតរបស់ខ្ញុំ វាទាក់ទងផ្លែម្នាស់ ។ នៅក្នុងទ្វីបអឺរ៉ុប អ្នកនឹងរកឃើញ ផ្លែម្នាស់នៅលើទីផ្សារ មកពីប្រទេសនានា។ ពេលខ្លះ ហាងនឹងបញ្ជាក់ថា វាជាម្នាស់មកពីប្រទេសហ្កាណា មកពីអាមេរិកកណ្តាល ឬ មកពីប្រទេសកូតឌីវ័រ ប៉ុន្តែតាមដែលខ្ញុំដឹង បច្ចុប្បន្ននេះមានតែកូតឌីវ័រ ដែល

© WIPO/OMPI

មានដាក់ស្លាក "ផ្លែម្នាស់មកពីប្រទេសកូតឌីវ័រ" និងហាងមួយចំនួនបានសង្កេតឃើញថា អតិថិជនកំពុងស្វែងរក ផ្លែម្នាស់ទាំងនោះជាពិសេស។ បែបនេះមិនមែនជាពាណិជ្ជសញ្ញាទេ វាជាម៉ាកបញ្ជាក់ពីចរិតលក្ខណៈទំនិញនិងសេវា (certification mark) មួយ ប៉ុន្តែវាត្រូវបានចុះបញ្ជីជាពាណិជ្ជសញ្ញា ហើយអ្នកនាំចេញពីកូតឌីវ័រ អាចប្រើស្លាកនេះ ដើម្បីបែងចែកផលិតផលរបស់ខ្លួនពីផ្លែម្នាស់នៃផលិតករបរទេសផ្សេងទៀត។ហើយខ្ញុំជឿថា ប្រទេសកំពុងអភិវឌ្ឍ នឹងទទួលបានអត្ថប្រយោជន៍កាន់តែច្រើនពីការហៅប្រភពភូមិសាស្ត្រទំនិញ (appellations of origin) ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ (geographical indications) ឬពាណិជ្ជសញ្ញាដែលជាមធ្យោបាយនៃការលក់ទំនិញរបស់ពួកគេ ដូចជាផលិតផលក្នុងស្រុកមិនដូចជាទំនិញស្តង់ដាដែលគ្មានការកំណត់ប្រភពអត្តសញ្ញាណច្បាស់លាស់ ។

© WIPO/OMPI

មានយន្តការជាច្រើន សម្រាប់ទទួលការបង់ប្រាក់ ពីអ្នកដែលប្រើប្រាស់កម្មសិទ្ធិបញ្ញារបស់គេ ហើយសម្លេងថតបន្ទាប់នឹងពិភាក្សា ពីយន្តការខ្លះៗទាំងនោះ។

**សម្លេងទី ៣:** *វាក្យសព្ទការផ្តល់អាជ្ញាប័ណ្ណ និង ការបង់ថ្លៃសិទ្ធិជាញឹកញាប់មានទំនាក់ទំនងជាមួយនឹងការធ្វើអាជីវកម្ម ឬ ទីផ្សារនៃកម្មសិទ្ធិបញ្ញា ។ តើអ្វីជាភាពខុសគ្នារវាងផ្តល់អាជ្ញាប័ណ្ណនិងការបង់ថ្លៃសិទ្ធិ* (លាភការ)*?*

ការផ្តល់អាជ្ញាប័ណ្ណ គឺជាដំណើរការដែលអ្វីមួយគឺត្រូវបានអនុញ្ញាត។ វាជាការផ្តល់ការអនុញ្ញាត ។ វាមកពីនាមសព្ទភាសាឡាតាំង licentia មានន័យថាការអនុញ្ញាត ។ ម្ចាស់សិទ្ធិកម្មសិទ្ធិបញ្ញា ឬ IPR គឺជាបុគ្គលតែម្នាក់គត់ ដែលអាចអនុញ្ញាតឲ្យមានការប្រើប្រាស់ IPRទៅនរណាម្នាក់ផ្សេងទៀត។ ប្រសិនបើនរណាម្នាក់ចង់ប្រើបច្ចេកវិទ្យារបស់ខ្ញុំ គាត់ត្រូវធ្វើកិច្ចព្រមព្រៀងអាជ្ញាប័ណ្ណ ទម្រង់នៃការរៀបចំកិច្ចសន្យាជាមួយខ្ញុំ ហើយកិច្ចព្រមព្រៀងនោះនឹងបញ្ជាក់ពីលក្ខខណ្ឌ ដែលគាត់នឹងប្រើសិទ្ធិកម្មសិទ្ធិបញ្ញារបស់ខ្ញុំ ពោលគឺរបៀបដូចម្តេច ទីកន្លែងណា និងពេលណា ។ ចំនួនទឹកប្រាក់សម្រាប់ការអនុញ្ញាតដោយច្បាប់ ហើយវាគឺវាជាវិធីស្របច្បាប់នៃការធ្វើអាជីវកម្មកម្មសិទ្ធិបញ្ញា ។ ប្រសិនបើនរណាម្នាក់ ប្រើកម្មសិទ្ធិបញ្ញារបស់ខ្ញុំ និយាយបានថាបច្ចេកវិទ្យារបស់ខ្ញុំ ការច្នៃប្រឌិតរបស់ខ្ញុំ ឬ ពាណិជ្ជសញ្ញារបស់ខ្ញុំដោយគ្មានការការអនុញ្ញាត - វាគឺជាការខុសច្បាប់ វាជាការរំលោភបំពាន ឬ ទង្វើនៃការលួចចម្លង ហើយវាក្លាយជាស្របច្បាប់ ប្រសិនបើនៅពេលដែលគាត់ធ្វើកិច្ចព្រមព្រៀងអាជ្ញាប័ណ្ណជាមួយខ្ញុំ។

ផ្ទុយមកវិញ ការបង់ថ្លៃសិទ្ធិ គឺការបង់ប្រាក់ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងអាជ្ញាប័ណ្ណ ជាធម្មតាបានគណនាជាភាគរយនៃចំនួនឯកតា ឬ បរិមាណ ដែលត្រូវបានផលិតនៅក្រោមអាជ្ញាប័ណ្ណ។ ឧទាហរណ៍ ប្រសិនបើអ្នកផ្តល់អាជ្ញាប័ណ្ណផលិតសំបកកង់ ទៅនរណាម្នាក់នោះ អ្នកមានវិធីពីរយ៉ាងនៃការកំណត់តម្លៃក្នុងកិច្ចព្រមព្រៀងអាជ្ញាប័ណ្ណ។ អ្នកជ្រើសរើសយកបង់ដុលក៏បាន ក្នុងករណីអ្នកសម្រេចចិត្តថាបច្ចេកវិទ្យា និង ចំណេះធ្វើរបស់អ្នក គឺមានតម្លៃមួយលានដុល្លារ ហើយកិច្ចព្រមព្រៀងបញ្ជាក់អំពីរបៀបដែលអ្នកទទួលអាជ្ញាប័ណ្ណនេះ គឺបង់មួយលានដុល្លារ ឬ អ្នកផ្តល់សម្រាប់ការបង់ថ្លៃសិទ្ធិក៏បាន ដែលមានការបង់ជាទៀងទាត់នៃការទូទាត់សំណង ផ្អែកលើបរិមាណផលិត ឬ លើកត្តាផ្សេងទៀត ។

ការបង់ថ្លៃសិទ្ធិ ត្រូវបានប្រើដោយអ្នកផ្តល់អាជ្ញាប័ណ្ណ ពេលដែលពួកគេចង់គ្រប់គ្រងលើលទ្ធផលរបស់អ្នកទទួលអាជ្ញាប័ណ្ណ និង ក៏ដើម្បីគុណភាពរបស់ខ្លួន ដោយសារតែ

© WIPO/OMPI

បរិមាណនៃការការបង់ថ្លៃសិទ្ធិជាការចង្អុលបង្ហាញពីតម្លៃអ្នកទទួលអាជ្ញាប័ណ្ណផលិត និង មធ្យោបាយចុងក្រោយនៃការពិនិត្យមើល លើសមត្ថភាពផលិតរបស់អ្នកទទួលអជ្ញាបណ្ណ័។ សម្រាប់អ្នកទទួលអាជ្ញាប័ណ្ណ អត្ថប្រយោជន៍នៃការយល់ព្រមលើការបង់ថ្លៃសិទ្ធិ គឺថាចំនួន បង់សម្រាប់បច្ចេកវិទ្យាត្រូវមានរយៈពេលច្រើនឆ្នាំ ហើយផលប្រយោជន៍ ដែលគាត់បាន កើតចេញមកពីអាជ្ញាប័ណ្ណ អាស្រ័យលើទិន្នផលរបស់គាត់។ វាជាការគ្មានប្រយោជន៍ ប្រសិនបើអ្នកទទួលអាជ្ញាប័ណ្ណ បង់ចំនួនទឹកប្រាក់ដ៏ធំសម្បើមដូចជាកម្រៃបច្ចេកវិទ្យាដែល យើងហៅថាការបង់ថ្លៃសិទ្ធិដុល ហើយបន្ទាប់មកមិនប្រើបច្ចេកវិទ្យាដើម្បីទទួលបានផល ចំណូលពីការវិនិយោគនោះ។

© WIPO/OMPI

មានការប្រឹងប្រែងជាច្រើន ដើម្បីជួយអ្នកបង្កើតកម្មសិទ្ធិបញ្ញាដើម្បីបង្វែរសិទ្ធិរបស់ពួកគេចូលក្នុងផលិតផលពាណិជ្ជកម្មឲ្យទទួលបានជោគជ័យ ។ សម្លេងថតបន្ទាប់នឹងពិពណ៌នាពី ការបង្កើតនៃមជ្ឈមណ្ឌលការបង្កើតថ្មី ។

**សម្លេងទី ៤**: *តើអ្នកអាចប្រាប់យើងខ្លះៗ អំពីមជ្ឈមណ្ឌលការបង្កើតថ្មី ?*

មជ្ឈមណ្ឌលការបង្កើតថ្មីគឺជាគំនិតមួយ ដែលបានផុតឡើងនៅចុងសតវត្សទី ៧០ និងសតវត្ស ៨០ នៅក្នុងប្រទេសឧស្សាហកម្មមួយចំនួន។ ជាទូទៅ ពួកវាបានបង្ហាញខ្លួនជាលើកដំបូងក្នុងការផ្សំគ្នាជាមួយការស្រាវជ្រាវនៅសាកលវិទ្យាល័យ ឬ មូលនិធិមន្ទីរពិសោធន៍ស្រាវជ្រាវរបស់រដ្ឋាភិបាលនៅអឺរ៉ុបខាងលិច និងអាមេរិកខាងជើង។ មុខងារចំបង់របស់មជ្ឈមណ្ឌលការបង្កើតថ្មី គឺការនាំបច្ចេកវិទ្យាថ្មី និង ការអភិវឌ្ឍថ្មីពីតុអ្នកស្រាវជ្រាវ ឬ មន្ទីរពិសោធន៍ទៅក្នុងទីផ្សារ ។ វាមានភាពងាយស្រួលក្នុងការនិយាយថា អ្នកត្រូវតែផ្ទេរបច្ចេកវិទ្យា ។ តាមពិត វាជាការលំបាកខ្លាំងណាស់ដើម្បីធ្វើវា ព្រោះដំណាក់កាលនៃការអភិវឌ្ឍនៃការច្នៃប្រឌិតមួយនឹងមានឥទ្ធិពលយ៉ាងខ្លាំងពីថ្លៃដើមនៃការផ្ទេរនេះ។

ប្រសិនបើអ្នកមាន ការច្នៃប្រឌិតមួយដែលត្រូវបានបង្ហាញថាថ្មី ដូច្នេះអាចទទួលប្រកាសនីយបត្រកត្តកម្ម ហើយអ្នកបានទទួលប្រកាសនីយបត្រកត្តកម្ម អ្នកបានឆ្លងជំហានដំបូង ប៉ុន្តែនេះមិនមែនមានន័យថា បច្ចេកវិទ្យានេះនឹងដំណើរការយ៉ាងពិតប្រាកដទេ ។ វាអាចធ្វើការបានយ៉ាងល្អនៅក្នុងលក្ខខណ្ឌមន្ទីរពិសោធន៍ ប៉ុន្តែមិនដែលធ្វើសោះនៅក្នុងការអនុវត្តបែបឧស្សាហកម្ម។ ពេលខ្លះទីផ្សារ គឺមិនទាន់ត្រៀមខ្លួនជាស្រេចដើម្បីទទួលវា។ ពេលខ្លះ លក្ខខណ្ឌផ្សេងទៀត ឬ កត្តាមនុស្សរំខាន និងអ្នកមិនអាចផ្ទេរបច្ចេកវិទ្យាបាន ។ ដូច្នេះជាការពិត មជ្ឈមណ្ឌលការបង្កើតថ្មីគឺស្រដៀងគ្នាទៅនឹងមជ្ឈមណ្ឌលភ្ញាស់អាជីវកម្មរបស់រដ្ឋាភិបាល ឬ សភាពាណិជ្ជកម្ម ។

មជ្ឈមណ្ឌលការបង្កើតថ្មីនេះនឹងជួយអ្នកបង្កើតថ្មី ឬ អ្នកស្រាវជ្រាវនាំមកនូវការបង្កើតថ្មីរបស់គាត់ ឬ IPR ផ្សេងទៀតទៅក្នុងទីផ្សារ ។ វាអាចផ្តល់នូវសេវាកម្មផ្សេងៗជាច្រើនដូចជា ដំបូន្មានកម្មសិទ្ធិបញ្ញា ការវាយតម្លៃលើការច្នៃប្រឌិតសម្រាប់កំណើនសេដ្ឋកិច្ច និង បច្ចេកទេសដែលអាចធ្វើទៅបាន ឬ ទាក់ទងទៅនឹងបរិស្ថានច្បាប់ ដែលក្នុងនោះការច្នៃប្រឌិតត្រូវអនុវត្ត ហើយវាជួយអ្នកបង្កើតថ្មី ឬ អ្នកស្រាវជ្រាវនៅក្នុងអភិវឌ្ឍផែនការអាជីវកម្មមួយ ដែលទាក់ទាញវិនិយោគិននិង ផលិតករ កាន់តែងាយស្រួល ដូចជាផែនការអាជីវកម្ម

© WIPO/OMPI

មួយដែល បានផ្តល់ជាគំនិតល្អប្រសើរជាងមុនពីរបៀបការច្នៃប្រឌិតអភិវឌ្ឍ និង ត្រូវបានធ្វើអាជីវកម្មដូចផលិតផលមានទីផ្សារ។ ជាធម្មតា វាដើរតួធ្វើជាស្ពានរវាងការស្រាវជ្រាវ និងការអភិវឌ្ឍនៅលើដៃម្ខាង ហើយការផលិតនៅលើដៃម្ខាងទៀត។

*ដូច្នេះតាមវិធីនេះ តើមជ្ឈមណ្ឌលការបង្កើតថ្មីគឺជាការព្យាយាមប្រែក្លាយកម្មសិទ្ធិបញ្ញា ទៅជាមូលធនបញ្ញាមែនទេ ?*

នោះជាការត្រឹមត្រូវ។ វាមែនទែនទៅមជ្ឈមណ្ឌលការបង្កើតថ្មីគឺធ្វើការជួយសម្រួលដល់ការផ្ទេរការច្នៃប្រឌិតពីដំណាក់កាលស្រាវជ្រាវចូលទៅក្នុងទីផ្សារ។ មានមជ្ឈមណ្ឌលការបង្កើតថ្មីជោគជ័យជាច្រើននៅតាមបណ្តាសាកលវិទ្យាល័យ មិនត្រឹមតែមាននៅក្នុងបណ្តាប្រទេសឧស្សាហកម្មទេ ប៉ុន្តែក៏មាននៅប្រទេសម៉ិកស៊ិក្ខ ប្រទេសប្រេស៊ីល និងប្រទេសអាហ្សង់ទីន ហើយខ្ញុំបានឮថាពួកវាក៏មាននៅក្នុង បណ្តាប្រទេសជាច្រើននៃទ្វីបអាស៊ីដែរ។

ភារកិច្ចរបស់យើងនៅអង្គការកម្មសិទ្ធិបញ្ញាពិភពលោក គឺដើម្បីជំរុញលើកទឹកចិត្តដល់ប្រទេសកំពុងអភិវឌ្ឍក្នុងការបង្កើតមជ្ឈមណ្ឌលការបង្កើតថ្មី ជារចនាសម្ព័ន្ធដែលនឹងជួយសម្របសម្រួលដល់ទីផ្សារក្នុងការវិនិយោគបញ្ញា ពាក្យម្យ៉ាងទៀតលទ្ធផលស្រាវជ្រាវសម្រេចបាននៅមន្ទីរពិសោធន៍ស្រាវជ្រាវជាតិ ឬសាកលវិទ្យាល័យ ឬដោយអ្នកច្នៃប្រឌិតក្នុងស្រុក។

© WIPO/OMPI

# សង្ខេបបញ្ចប់

តាមរយៈការសិក្សាម៉ូឌុលជាច្រើនរបស់អ្នក អ្នកបានរៀនអំពីប្រភេទផ្សេងៗគ្នានៃកម្មសិទ្ធិបញ្ញានិងប្រភេទផ្សេងគ្នានៃកិច្ចការពារ។ ម៉ូឌុលនេះបានសង្កត់ធ្ងន់ពីអត្ថប្រយោជន៍នៃកិច្ចការពារជាច្រើន ក្នុងខណៈជាអ្នកកាន់កាប់សិទ្ធិ។ ជាមូលដ្ឋាន នៅក្នុងប្រធានបទទាំងអស់នៃការពន្យល់ គឺថាអ្នកបង្កើតកម្មសិទ្ធិបញ្ញាអាចទទួលផលតបស្នងជាហិរញ្ញវត្ថុ តាមការធ្វើការអនុវត្តសិទ្ធិរបស់ពួកគេ។ គ្រាន់តែជាម្ចាស់កម្មសិទ្ធិបញ្ញា មិនបង្កើតលុយទេ។ ដើម្បីធ្វើដូចនេះ ម្ចាស់នៃសិទ្ធិត្រូវតែទាញយកវាតាមរយៈហិរញ្ញវត្ថុប្រភេទផ្សេងៗគ្នានៃការចុះកិច្ចព្រមព្រៀងពាណិជ្ជកម្ម រួមទាំងការរៀបចំផ្តល់អាជ្ញាប័ណ្ណ និង ការលក់សិទ្ធិ ។ នៅក្នុងន័យនេះ គ្រប់កិច្ចព្រមព្រៀងពាណិជ្ជកម្មទាំងនេះគឺជាការព្យាយាមប្រែក្លាយកម្មសិទ្ធិបញ្ញាទៅជាមូលធនបញ្ញា ។

អ្នកបានរៀនអំពីរចនាសម្ព័ន្ធទូទៅនៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងបានសិក្សាពីទិដ្ឋភាពទូទៅនៃ

- ស្នាដៃមួយត្រូវបានការពារដោយ សិទ្ធិអ្នកនិពន្ធ
- សិទ្ធិផ្តល់ទៅឲ្យម្ចាស់សិទ្ធិអ្នកនិពន្ធ
- ដែនកំណត់លើសិទ្ធិទាំងនោះ
- ភាពជាម្ចាស់ និងការផ្ទេរសិទ្ធិអ្នកនិពន្ធ និង
- ការអនុវត្តសិទ្ធិ ។

អនុសញ្ញា Berneបានថ្លែងថាសិទ្ធិអ្នកនិពន្ធគ្របដណ្តប់"រាល់ការផលិតនៅក្នុងវិស័យអក្សរសាស្ត្រ វិទ្យាសាស្ត្រ និង សិល្បៈ អ្វីៗក៏អាចជារបៀប ឬ ទម្រង់នៃការបញ្ចេញគំនិត" ។ តាមន័យទូលាយ គឺគ្រប់ស្នាដៃដើមនៃការនិពន្ធ ដោយមិនគិតពីលក្ខណៈសម្បត្តិរបស់អក្សរសាស្ត្រ ឬ សិល្បៈ ។ ម្ចាស់សិទ្ធិអ្នកនិពន្ធក្នុងស្នាដៃត្រូវបានការពារ អាចប្រើស្នាដៃតាមបំណង និងអាចការពារអ្នកដទៃពីការប្រើវាដោយគ្មានការអនុញ្ញាត ។ សិទ្ធិទាំងនេះត្រូវបានសំដៅទៅលើ "សិទ្ធិផ្តាច់មុខ" ។ សិទ្ធិអ្នកនិពន្ធការពារទាំងពីរ សិទ្ធិសេដ្ឋកិច្ច និង សិទ្ធិសីលធម៌។

បន្ថែមលើអ្វីដែលបានរៀបរាប់ខាងលើ កិច្ចព្រមព្រៀង TRIPS បានបញ្ចូលប្រភេទមួយផ្សេងទៀតនៃការងារ ដែលត្រូវបានគ្របដណ្តប់នៅក្រោមសិទ្ធិអ្នកនិពន្ធ។ វាគឺជាការផលិតពហុព័ត៌មាន និងទោះបីជាគ្មាននិយមន័យផ្លូវច្បាប់ណាក៏ដោយ មានការយល់ស្របគ្នាថា ការរួមបញ្ចូលគ្នានៃ សំឡេង អត្ថបទ និងរូបភាពនៅក្នុងទ្រង់ទ្រាយឌីជីថល ដែលត្រូវ

© WIPO/OMPI

បានធ្វើឡើងអាចដំណើរការដោយកម្មវិធីកុំព្យូទ័រមួយ ត្រូវបានចាត់ទុកជាការបញ្ចេញគំនិតដើមនៃការនិពន្ធ និងត្រូវបានគ្របដណ្តប់ដោយសិទ្ធិអ្នកនិពន្ធ។

សិទ្ធិប្រហាក់ប្រហែល ក៏បានសំដៅដល់សិទ្ធិជិតខាង ឬ ពិសេសជាងនេះ "សិទ្ធិជិតខាងរបស់សិទ្ធិអ្នកនិពន្ធ" ការពារផលប្រយោជន៍ស្របច្បាប់របស់បុគ្គលណាមួយ ឬ អង្គការណាដែលបានរួមចំណែកធ្វើឲ្យស្នាដៃនេះមានដល់សាធារណជន ឬ បុគ្គលទាំងឡាយណាដែលបន្ថែមភាពច្នៃប្រឌិត បច្ចេកទេស ឬ ជំនាញរៀបចំ ។

តាមទំលាប់ សិទ្ធិប្រហាក់ប្រហែលត្រូវបានផ្តល់ជូនអ្នកទទួលផលបីប្រភេទគឺៈ អ្នកសម្តែង ផលិតករ និង អ្នកផ្សព្វផ្សាយ ។ តម្រូវការសម្រាប់កិច្ចការពារស្របច្បាប់នៃក្រុមទាំងបីនេះ ត្រូវបានបានកំណត់នៅក្នុងអនុសញ្ញាទីក្រុងរ៉ូមក្នុងឆ្នាំ ១៩៦១ ដែលជាការប្រឹងប្រែងបង្កើតបទប្បញ្ញត្តិអន្តរជាតិនៅក្នុងវិស័យថ្មីមួយ ដែលច្បាប់ជាតិមានជាធរមាន។ ម្យ៉ាងទៀត រដ្ឋភាគច្រើន ជាធម្មតាបានពង្រាង និង អនុម័តច្បាប់ មុនពេលប្រកាន់យកអនុសញ្ញានេះ។ អនុសញ្ញាទីក្រុងរ៉ូម ទោះបីជាមិនល្អឥតខ្ចោះ និងត្រូវការពិនិត្យឡើងវិញ គឺនៅតែជាគោលអន្តរជាតិសម្រាប់កិច្ចការពារក្នុងវិស័យនេះ។ ដូចជាច្បាប់សិទ្ធិអ្នកនិពន្ធ អនុសញ្ញាទីក្រុងរ៉ូម និងច្បាប់ជាតិមានដែនកំណត់លើសិទ្ធិ អនុញ្ញាតសម្រាប់ការប្រើប្រាស់លក្ខណៈឯកជន ការប្រើប្រាស់សេចក្តីដកស្រង់ខ្លីៗ និងការប្រើប្រាស់ស្នាដៃរក្សាសិទ្ធិសម្រាប់ការបង្រៀន ឬ ការស្រាវជ្រាវវិទ្យាសាស្ត្រ ។

ថិរវេលានៃកិច្ចការពារសិទ្ធិប្រហាក់ប្រហែល ដូចបានចែងនៅក្នុងអនុសញ្ញទីក្រុងរ៉ូម គឺ ២០ ឆ្នាំចាប់ពីចុងឆ្នាំនោះនៃៈ

- ការថតសម្លេងត្រូវបានធ្វើ
- ការសម្តែងបានធ្វើឡើង
- ការចាក់ផ្សាយបានកើតមាន ។

ការអភិរក្ស ឬ វិធានការបណ្តោះអាសន្ន សំដៅយកការដោះស្រាយសំណងសម្រាប់ការរំលោភបំពាន ឬ ការរំលោភលើសិទ្ធិប្រហាក់ប្រហែល ។ ទាំងនេះរួមមាន សំណងរដ្ឋប្បវេណី ទណ្ឌកម្មព្រហ្មទណ្ឌ វិធានការតាមមាត់ច្រកព្រំដែននិងវិធានការផ្សេងៗ សំណង និង ទណ្ឌកម្មប្រឆាំងនឹងការរំលោភបំពាននៃឧបករណ៍បច្ចេកទេស ។

សិទ្ធិប្រហាក់ប្រហែល ក៏ការពារយ៉ាងទូលំទូលាយាពីការបញ្ចេញគំនិតវប្បធម៌ (Culture expression) ដែលមិនបានសរសេរ និង មិនបានកត់ត្រាទុករបស់ប្រទេសកំពុងអភិវឌ្ឍជាច្រើនទៀត។ កិច្ចការពារសិទ្ធិប្រហាក់ប្រហែលបានក្លាយជាផ្នែកនៃរូបភាពធំមួយ និង ជាបុរេលក្ខខណ្ឌចាំបាច់ ដើម្បីចូលរួមក្នុងប្រព័ន្ធគំហើញថ្មីរបស់ពាណិជ្ជកម្មអន្តរជាតិ

© WIPO/OMPI

និង ការវិនិយោគ។

ផ្នែកប្រកាសនីយបត្រតក្កកម្មនៃកម្មសិទ្ធិបញ្ញា មានព័ត៌មានជាមូលដ្ឋាន ។ ប្រកាសនីយបត្រតក្កកម្ម គឺជាទម្រង់ចំណាស់ជាងគេរបស់កិច្ចការពារកម្មសិទ្ធិបញ្ញានិងដូចទម្រង់ទាំងអស់នៃកិច្ចការពារកម្មសិទ្ធិបញ្ញា គោលបំណងនៃប្រព័ន្ធប្រកាសនីយបត្រតក្កកម្ម គឺដើម្បីជំរុញលើកទឹកចិត្តដល់ការអភិវឌ្ឍសេដ្ឋកិច្ច តាមការផ្តល់រង្វាន់ច្នៃប្រឌិតបញ្ញា ។ ផ្នែកនេះបានពន្យល់ថា គោលបំណងរបស់ប្រកាសនីយបត្រតក្កកម្ម គឺដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចដោយផ្តល់រង្វាន់ទៅការច្នៃប្រឌិតផ្នែកបញ្ញា ។

ក្រោមកិច្ចការពារប្រកាសនីយបត្រតក្កកម្ម ទាំងការបង្កើតនិងការអភិវឌ្ឍបន្តត្រូវបានគ្របដណ្តប់ ។ របកគំហើញវិទ្យាសាស្ត្រដូចជា ការបង្កើតថ្នាំ ប៉េនីស៊ីលីន (Penicillin) គឺមានសារៈសំខាន់ និង ការពារស្មើគ្នា ដូចគ្នាការច្នៃម៉ាស៊ីនមួយឲ្យដំណើរការលឿនជាងមុន។ ប្រកាសនីយបត្រតក្កកម្មការពារការច្នៃប្រឌិត និង ក្នុងន័យសាមញ្ញ ការច្នៃប្រឌិតមួយអាចត្រូវបានកំណត់ថាជាដំណោះស្រាយថ្មីសម្រាប់បញ្ហាបច្ចេកទេសមួយ។ ដំណោះស្រាយ គឺជា "គំនិត" និង កិច្ចការពារក្រោមច្បាប់ប្រកាសនីយបត្រតក្កកម្មមិនទាមទារថាការប្រឌិតឡើងមានជារូបរាងទេ។ ទោះយ៉ាងណាមានវិធាននិងករណីលើកលែង ចំពោះរឿងទាំងឡាយ ដែលមិនអាចត្រូវបានផ្តល់ប្រកាសនីយបត្រតក្កកម្ម ។ ទាំងនេះរួមមាន: ហ្សែនមនុស្ស អ្វីៗដែលបានរកឃើញក្នុងធម្មជាតិ និងម៉ាស៊ីនដែលប្រឆាំងនឹងច្បាប់ធម្មជាតិដូចជាម៉ាស៊ីនមានចលនាមិនដាច់។ ការបដិសេធផ្សេងៗទៀត ដែលស្ថិតនៅក្រោមច្បាប់ជាតិជាទូទៅគឺទ្រឹស្តីវិទ្យាសាស្ត្រ និង រូបមន្តគណិតវិទ្យា គម្រោង វិធាន និង វិធីសាស្ត្រធ្វើពាណិជ្ជកម្ម និង វិធីសាស្ត្រព្យាបាលមនុស្ស ឬ សត្វ ឬ វិធីសាស្ត្រវិនិច្ឆ័យរោគ ។

នៅពេលដែលតក្កកម្មមួយបានដាក់ពាក្យ វាត្រូវបានពិនិត្យឡើងវិញ និង ត្រួតពិនិត្យដោយអ្នកបច្ចេកទេសជំនាញ ដើម្បីធានាថាវាឆ្លើយតបតាមតម្រូវការនៃប្រកាសនីយបត្រតក្កកម្ម។ ចរិតលក្ខណៈដែលការច្នៃប្រឌិតមួយត្រូវមានគឺ: (១)វាត្រូវតែថ្មី ឬ របស់ថ្មី (២) វាត្រូវតែមានជំហានរកឃើញថ្មី (៣) វាត្រូវតែយកទៅអនុវត្តបាននៅក្នុងឧស្សាហកម្ម ។ ជាសង្ខេប ប្រកាសនីយបត្រតក្កកម្ម គឺជាកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលជាតិ និងអ្នកច្នៃប្រឌិត។ រដ្ឋផ្តល់កិច្ចការពារសម្រាប់រយៈពេលកំណត់ណាមួយ ដែលធានាថាអ្នកច្នៃប្រឌិតទទួលបានផលតបស្នង ។ បន្ទាប់ពីផុតកំណត់ ជាធម្មតាមានរយៈពេល ២០ ឆ្នាំ ក្រោយពីអស់សុពលភាពប្រកាសនីយបត្រតក្កកម្ម ការច្នៃប្រឌិតនោះគឺអាចប្រើបានគ្រប់គ្នា ។ ដោយសារគ្មានកិច្ចការពារទូទាំងពិភពលោក អ្នកច្នៃប្រឌិតម្នាក់ត្រូវតែបង់ថ្លៃដាក់ពាក្យស្នើសុំ និងថ្លៃការពារប្រចាំឆ្នាំតាមប្រទេសនីមួយៗដែលគាត់មានបំណងការពារ ។

© WIPO/OMPI

នៅក្នុងម៉ូឌុលពីពាណិជ្ជសញ្ញា អ្នកបានរៀនថាពាណិជ្ជសញ្ញាគឺជា ពាក្យមួយម៉ាត់ ឡូហ្គោមួយ លេខមួយ អក្សរមួយតួ ពាក្យស្លោកមួយ សំឡេងមួយ ពណ៌មួយ ឬ ពេលខ្លះសូម្បីតែក្លិនដែលបញ្ជាក់ពីប្រភពនៃទំនិញនិង/ឬ សេវាដែលពាណិជ្ជសញ្ញានោះត្រូវបានប្រើ។

ពាណិជ្ជសញ្ញាគឺជាផ្នែកមួយនៃកម្មសិទ្ធិបញ្ញា ហើយគោលបំណងរបស់ពួកវាគឺដើម្បីការពារឈ្មោះរបស់ផលិតផល ជាជាងការច្នៃប្រឌិត ឬ គំនិតនៅពីក្រោយផលិតផល។ និយាយជារួម ពាណិជ្ជសញ្ញាគួរតែមានលក្ខណៈញែកដាច់ និងមិនគួរមានលក្ខណៈបោកបញ្ឆោត ។

ការប្រើប្រាស់ទំនិញសម្គាល់ភូមិសាស្ត្រ ជាវិធីសាស្ត្រមួយដ៏សំខាន់ក្នុងការបង្ហាញប្រភពដើមនៃទំនិញនិង សេវាកម្ម។ មួយក្នុងចំណោមគោលបំណងនៃការប្រើប្រាស់របស់ពួកវា គឺលើកកម្ពស់ពាណិជ្ជកម្មដោយការផ្តល់ព័ត៌មានប្រភពដើមរបស់ផលិតផលនេះដល់អតិថិជន ។ ជាញឹកញាប់នេះអាចបញ្ជាក់គុណភាពជាក់លាក់មួយ ដែលអតិថិជនកំពុងស្វែងរក ។ ពួកគេអាចប្រើសម្រាប់ផលិតផលឧស្សាហកម្ម និង កសិកម្ម។ កិច្ចការពារ បែបនេះគឺ ឈរលើមូលដ្ឋានជាតិ ប៉ុន្តែមានសន្ធិសញ្ញាអន្តរជាតិជាច្រើន ដែលជួយដល់កិច្ចការពារនៅបណ្តាប្រទេសជាច្រើន។

អ្នកបានរៀនផងដែរ អំពីសន្ធិសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោកទាក់ទងនឹងប្រព័ន្ធចុះបញ្ជីអន្តរជាតិសម្រាប់កិច្ចការពារពាណិជ្ជសញ្ញា និងគំនូរឧស្សាហកម្ម។ តួនាទីរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកនៅក្នុងដំណើរការនេះគឺធ្វើជាអ្នកគ្រប់គ្រង ការពារប្រព័ន្ធមនៃចុះបញ្ជី។

ប្រព័ន្ធម៉ាឌ្រីដត្រូវបានបង្កើតឡើងលើសពី ១០០ ឆ្នាំ ហើយគោលបំណងរបស់វាគឺតាមដានការចុះបញ្ជីម៉ាកជាលក្ខណៈអន្តរជាតិ ។ ប្រសិនបើ បុគ្គលម្នាក់ចង់បានកិច្ចការពារពាណិជ្ជសញ្ញារបស់ខ្លួននៅក្នុងប្រទេសជាច្រើន ដំបូងគាត់ត្រូវតែចុះបញ្ជីវានៅក្នុងប្រទេសដើមរបស់គាត់។ វាមានភាពអាស្រ័យគ្នាសម្រាប់រយៈពេលប្រាំឆ្នាំ ប្រសិនបើពាណិជ្ជសញ្ញាត្រូវបានបដិសេធនៅក្នុងប្រទេសដើម ប៉ុន្តែទទួលបានការចុះបញ្ជីនៅក្នុងប្រទេសដែលបានជ្រើសរើសយកផ្សេងទៀត វានឹងត្រូវលុបចោលដូចគ្នា។ កិច្ចការពារម៉ាកជាលក្ខណៈអន្តរជាតិគឺមិនកាលកំណត់ ដរាបណាវាត្រូវតែចុះបញ្ជីសារឡើងវិញរៀងរាល់ដប់ឆ្នាំម្តង ។ វាគ្មានកំណត់ចំនួនដងដែលត្រូវចុះបញ្ជីសារឡើងវិញទេ។

កិច្ចព្រមព្រៀងទីក្រុងហាច (Hague Agreement) បានបង្កើតប្រព័ន្ធចុះបញ្ជីគំនូរឧស្សាហកម្មជាលក្ខណៈអន្តរជាតិ ។ គំនូរឧស្សាហកម្ម សំដៅទៅលើ រូបរាងរបស់វត្ថុមួយ

© WIPO/OMPI

ហើយវាខុសពីប្រកាសនីយបត្រតក្កកម្ម ។ ភាពខុសគ្នាដ៏សំខាន់ គឺថា ប្រកាសនីយបត្រតក្កកម្មមួយ ការពារបច្ចេកទេសនៃការច្នៃប្រឌិត និង ការបង្កើតថ្មី ខណៈពេលដែល គំនូរឧស្សាហកម្មការពាររូបរាងរបស់វត្ថុមួយ។ ម្ចាស់របស់គំនូរឧស្សាហកម្មត្រូវបានការពារសម្រាប់រយៈពេលមួយកំណត់។ ក្នុងប្រទេសភាគច្រើនកិច្ចការពារមានរយៈពេលដប់ឆ្នាំ ឬ សម្រាប់ដប់ប្រាំទៅម្ភៃឆ្នាំ។ វាមាន សេចក្តីបង្គាប់ថ្មី សម្រាប់ប្រទេសនៅក្នុងសហភាពអឺរ៉ុប ដែលផ្តល់ម្ចាស់គំនូរឧស្សាហកម្មនូវកិច្ចការពាររយៈពេល ម្ភៃប្រាំឆ្នាំ។

សន្ធិសញ្ញាសហប្រតិបត្តិប្រកាសនីយបត្រតក្កកម្ម(Patent Cooperation Treaty)ផ្តល់នីតិវិធីសាមញ្ញសម្រាប់អ្នកច្នៃប្រឌិត ឬ អ្នកស្នើសុំ ដើម្បីដាក់ពាក្យ និង ទទួលបានតក្កកម្មនៅក្នុងប្រទេសមួយចំនួនធំ។ លើសពីនេះទៀត វាជំរុញ និង សម្របសម្រួលការផ្លាស់ប្តូរព័ត៌មានបច្ចេកទេសដែលមាននៅក្នុងឯកសារតក្កកម្មទៅក្នុងឧស្សាហកម្ម និងអ្នកធ្វើការនៅក្នុងវិស័យជាក់លាក់នោះ។

ដើម្បីបំពេញ ការយល់ដឹងរបស់អ្នកពីវិសាលភាពកិច្ចការពារកម្មសិទ្ធិបញ្ញានៅលើទីផ្សារ អ្នកត្រូវបានបង្ហាញពីទស្សនៈទានពីអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និង ប្រភេទនៃទង្វើដែលអាចត្រូវបានចាត់ទុកថាការប្រកួតប្រជែងមិនស្មោះត្រង់ ដូចគ្នាដំណោះស្រាយដែលត្រូវបានប្រើដើម្បីធានាភាពយុត្តិធម៌ក្នុងការប្រកួតប្រជែង ។ គោលបំណងចំបងនៃច្បាប់ស្តីពី ការប្រកួតប្រជែងមិនស្មោះត្រង់ត្រូវបានគេពន្យល់ថា: កិច្ចការពារគូប្រកួតប្រជែង កិច្ចការពារអ្នកប្រើប្រាស់ និង ការពារការប្រកួតប្រជែងនៅក្នុងការចាប់អារម្មណ៍ពីសាធារណជនជាទ្រង់ទ្រាយធំ។ ដោយវិភាគពីប្រភេទផ្សេងៗគ្នានៃទង្វើដែលតាងឲ្យការប្រកួតប្រជែងមិនស្មោះត្រង់ អ្នកអាចយល់ពីការបំពេញបន្ថែមគ្នារវាង ច្បាប់កម្មសិទ្ធិបញ្ញា និងច្បាប់ការប្រកួតប្រជែងមិនស្មោះត្រង់។

ជាចុងក្រោយ អ្នកបានបញ្ចប់វគ្គសិក្សាណែនាំនេះដោយរៀនអំពីកិច្ចការពារពូជរុក្ខជាតិ ដែលជាទិដ្ឋភាពមួយផ្សេងទៀតនៃកម្មសិទ្ធិបញ្ញា ។ កិច្ចការពារ *sui generis* បានផ្តល់ពូជរុក្ខជាតិថ្មីៗ នៅពេលដែលពួកវាតបតាមលក្ខខណ្ឌជាក់លាក់ ស្វែងរកការទទួលស្គាល់សមិទ្ធិផលនៃការបង្កាត់ពូជដែលធ្វើការវិនិយោគសំខាន់នៅក្នុងវិស័យកសិកម្ម វិស័យសាកវប្បកម្ម និង ព្រៃឈើ ។ ឱកាសសម្រាប់ពួកគេទទួលបាន សិទ្ធិផ្តាច់មុខមួយជាក់លាក់ទាក់ទងទៅនឹងពូជរុក្ខជាតិថ្មី និងដូចជាការទាញយកការចំណាយថ្លៃដើមត្រលប់វិញ ផ្តល់នូវការលើកទឹកចិត្តមួយដ៏សំខាន់សម្រាប់សកម្មភាពតទៅមុខទៀត ដែលជាលទ្ធផលធ្វើឲ្យប្រសើរឡើងនូវគុណភាព និងសកម្មភាពនៃរុក្ខជាតិគ្រប់ប្រភេទ ។

© WIPO/OMPI